**សិក្ខាសាលាបែបអន្តរកម្ម**
**ស្តីពី**
**យុទ្ធសាស្ត្រការពារក្តី និងតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**កិច្ចសន្ទនាផ្នែកច្បាប់ ឆ្នាំ ២០១៣**

សហការរៀបចំដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

**នៅថ្ងៃអង្គារ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និងថ្ងៃពុធ ទី១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣**
**នៅសណ្ឋាគារអ៊ិនធើខនធីណិនថល លេខ ២៩៦ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ**

# ឯកសារសម្រាប់សិក្ខាសាលា


របៀបវារ.......................................................................................................................1
ការថ្លែងកត់សំគាលបើកកម្មវិធី .....................................................................................3
កិច្ចពិភាក្សាពេលព្រឹក៖ តំណាងដើមបណ្តឹងរដ្ឋប្បវេណី – សេចក្តីសង្ខេបនៃសកម្មភាពបែបអន្តរកម្ម .......10
កិច្ចពិភាក្សាពេលរសៀល៖ យុទ្ធសាស្រ្តការពារក្តី – សេចក្តីសង្ខេបនៃសកម្មភាពបែបអន្តរកម្ម ..............13

**សិក្ខាសាលាបែបអន្តរកម្ម**
**ស្តីពី**
**យុទ្ធសាស្ត្រការពារក្តី និងតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**កិច្ចសន្ទនាផ្នែកច្បាប់ ឆ្នាំ ២០១៣**

សហការរៀបចំដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
និងការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

**នៅថ្ងៃអង្គារ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និងថ្ងៃពុធ ទី១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣**
**នៅសណ្ឋាគារអ៊ិនធើខនធីណិនថល លេខ ២៩៦ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ**

# របៀបវារ

០៨:១៥-០៨:៤៥ ការចុះឈ្មោះអ្នកចូលរួម

---

ការពិភាក្សាពេលព្រឹក៖ **តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

អ្នកជំនាញ៖ លោក មេធាវី ពេជ្រ អង្គ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខជាតិ អ.វ.ត.ក និង លោកស្រី មេធាវី Elisabeth Simonneau-Fort សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំមុខអន្តរជាតិ អ.វ.ត.ក

០៩.០០ – ០៩.៣០ ការថ្លែងសុន្ទរកថាបើកកម្មវិធី និងសេចក្តីសង្ខេបស្តីពីសកម្មភាពនៃកិច្ចពិភាក្សា

០៩.៣០ – ១០.៤៥ សកម្មភាពបែបអន្តរកម្ម

១០.៤៥ – ១១.០០ សំរាកអាហារសំរ៉ន់

១១.០០ – ១១.៤៥ មតិឆ្លើយតបពីក្រុម និងមតិឆ្លើយតបរបស់អ្នកជំនាញ

១១.៤៥ – ១២.០០ សំណួរ និងចម្លើយ

---

១២.០០ – ១.៣០ សំរាកអាហារថ្ងៃត្រង់

ការពិភាក្សាពេលរសៀល៖ **យុទ្ធសាស្ត្រការពារក្តី**

អ្នកជំនាញ៖ លោក មេធាវី Victor Koppe សហមេធាវីអន្តរជាតិ សម្រាប់លោក នួន ជា អ.វ.ត.ក

\

១.៣០ – ២.០០ សុន្ទរកថាថ្លែងបើកកម្មវិធី និងសេចក្តីសង្ខេបស្តីពីសកម្មភាពនៃកិច្ចពិភាក្សា

២.០០ – ៣.១៥ សកម្មភាពបែបអន្តរកម្ម

៣.១៥ – ៣.៣០ សំរាកអាហារសំរ៉ន់

៣.៣០ – ៣.៥០ មតិឆ្លើយតបពីអ្នកជំនាញស្តីពីសកម្មភាពបែបអន្តរកម្ម

៣.៥០ – ៤.៣០ សំណួរ និងចម្លើយ

៤.៣០ ការវាយតម្លៃ

៤.៤៥ ការចែកវិញ្ញាបនបត្រ
វិញ្ញាបនបត្រនឹងចែកជូនដោយលោក កុយ នាម សមាជិកក្រុមប្រឹក្សា និងជា ប្រធានស្តីពីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

៥.០០ បញ្ចប់កម្មវិធី

***ការកត់សំគាល់៖*** *វិញ្ញាបនបត្រនឹងចែកជូនអ្នកចូលរួម នៅពេលបិទកម្មវិធីនៃកិច្ចពិភាក្សា។ អ្នកចូលរួមចាំបាច់ត្រូវចូលរួមទាំងវគ្គពេលព្រឹក និងរសៀលពេញ នៃសិក្ខាសាលានេះ ដើម្បីទទួលបានវិញ្ញាបនបត្ររបស់គេ។*

# ការថ្លែងកត់សំគាល់បើកកម្មវិធី

លោក មេធាវី ពេជ្រ អង្គ សហមេធាវីនាំមុខជាតិដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក

## ការតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសាលាក្តីខ្មែរក្រហម

### I. យុត្តិសាស្ត្រមួយចំនួន នៃភាគីដើមបណ្តឹងរដ្ឋប្បវេណី

**ក. គោលបំណងនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**

- ស្វែងរកយុត្តិធម៌តាមរយៈសាលក្រម និងមានការសម្រេចពីពិរុទ្ធភាព
- ដំណើរការក្តីមានលក្ខណៈត្រឹមត្រូវ និងអាចទទួលយកបាន
- បានចូលរួមក្នុងការបង្ហាញភស្តុតាង
- និយាយអំពីអ្វីដែលបានកើតឡើង
  សម្រាប់ជាភាពកតញ្ញូដល់ព្រលឹងអ្នកដែលបានស្លាប់ ឬព្រមទាំងឲ្យមនុស្សជំនាន់ក្រោយ សាធារណជន និងប្រទេសនានា យល់ពីភាពឃោឃៅ និងរួមគ្នាទប់ស្កាត់ អំពើដ៏សាហាវយង់ខ្នងកើតមានបន្តទៀត លើពិភពលោក
- មានសំណងប្រកបដោយអត្ថន័យ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រៅពីនោះ យើងក៏ចង់ឲ្យមានការគោរពសិទ្ធិរបស់ភាគី ទាំងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ជនជាប់ចោទផងដែរ
- ការផ្សះផ្សារជាតិ តាមរយៈការទទួលបាននូវយុត្តិធម៌
- អង្គហេតុដែលពាក់ព័ន្ធខ្លួនត្រូវបានយកមកនិយាយ
  ដើម្បីសម្រេចគោលបំណងទាំងនេះគេត្រូវមានយុត្តិសាស្ត្រ សម្រាប់សម្រេចគោលបំណងទាំងនេះ។ វិធានផ្ទៃក្នុងនៃអ.វ.ត.ក តម្រូវឲ្យធ្វើយុត្តិសាស្ត្រមួយ ដោយផ្តល់បន្ទុកនេះទៅមេធាវីនាំមុខជាអ្នកទទួលខុសត្រូវ (វិធាន១២ ស្ទួន២)។ ដោយកិច្ចការមានភាពស្មុគស្មាញជាខ្លាំង យើងបានជ្រើសរើស ធ្វើយុត្តិសាស្ត្រទៅតាមករណី និងមិនរៀបចំឲ្យមានអត្ថបទយុត្តិសាស្ត្ររួចស្រេចបាច់ទេ។

**ខ. យុត្តិសាស្ត្រ**

1. បែបបទធ្វើការងារផ្ទៃក្នុងរវាងមេធាវី៖
   a. លើកតម្កើងការយល់ដឹងរួមគ្នាតាមរយៈការសិក្សារួមគ្នាអំពីសំនុំរឿង ព្រមទាំងបញ្ហាច្បាប់ នានា
   b. បង្កើតឲ្យមានបែបបទក្នុងទំនាក់ទំនង និងធ្វើការងាររួមគ្នា ព្រមទាំងវិធីសាស្ត្រក្នុងការសម្រេចនានា និងតុល្យភាពនៃផលប្រយោជន៍ដែលតំណាងដោយក្រុមមេធាវី
   c. គោរពសិទ្ធិមេធាវីក្នុងការលើកពីផលប្រយោជន៍របស់កូនក្តី

2. ចំពោះដើមបណ្តឹងរដ្ឋប្បវេណី៖
   a. ធានាថាដើមបណ្តឹងរដ្ឋប្បវេណី បានយល់ពីសិទ្ធិរបស់ពួកគាត់
   b. ធានាថាពួកគាត់បានទទួលព័តមានពីបច្ចុប្បន្នភាពនៃរឿងក្តី
   c. ពិគ្រោះយោបល់កិច្ចការដែលពាក់ព័ន្ធនឹងផលប្រយោជន៍ និងលើកពីផលប្រយោជន៍ទាំងនេះ ទៅតុលាការ

   d. ជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីដែលមានភស្តុតាង/ព័ត៌មានល្អ និងអាចមានលទ្ធភាព និយាយកើតនៅចំពោះមុខអង្គសវនាការ
   e. បង្កើតឲ្យមានកម្មវិធីបន្សាំដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវផ្តល់សក្ខីកម្ម ដើម្បីឲ្យសក្ខីកម្មរបស់ពួកគាត់មានប្រសិទ្ធភាព

3. ការសម្របសម្រួលជាមួយសហព្រះរាជអាជ្ញា
   a. បង្កើតទំនាក់ទំនងញឹកញ៉ាប់ជាមួយសហព្រះរាជអាជ្ញា ដើម្បីចៀសវាង ការលើកនាំឲ្យខូចយុត្តសាស្ត្រ
   b. កំណត់ពីចំនុចដែលត្រូវលើក
      កំណត់ចំណាំ៖ វិធានផ្ទៃក្នុងនិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រការចោទប្រកាន់ ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណី មិនតម្រូវឲ្យយល់ព្រមតាមសហព្រះរាជអាជ្ញាលើគំនិតនានារបស់គាត់នោះឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណី នៅតែជាភាគីមួយឯករាជ្យ និងមានវិធីសាស្ត្រក្តីរបស់ខ្លួនដាច់ដោយឡែក។

4. ចំពោះភាគី និងអង្គជំនុំជម្រះ
   a. ធ្វើសំណើរសុំ និងការតវ៉ានានាដើម្បីឲ្យឲ្យសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាន គោរព
   b. ស្នើសុំឲ្យផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មផ្ទាល់មាត់ច្រើនគ្នា ក្នុងចំនួនសមស្រប និងលើអង្គហេតុ ព្រមទាំងព្យសនកម្មផ្សេងៗគ្នានៅក្នុង វិសាលភាពនៃសំនុំរឿង
   c. ធានាថាភស្តុតាង និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួល និងផ្តល់តម្លៃភស្តុតាងខ្ពស់
   d. បង្កើតគម្រោងសំណងឆ្លើយតមទៅនឹងបំណងប្រាថ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់បែបបទនៃសំណងគ្រប់ចំនួន ដើម្បីឲ្យចៅក្រមអាចទទួល ស្គាល់គម្រោងសំណងបាន

## II. ការចូលរួមជាភាគីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី

- **សិទ្ធិចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី:** ច្បាប់បង្កើតអ.វ.ត.ក មិនបាននិយាយអំពីការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីមិនបាននិយាយឲ្យច្បាស់លាស់ ជាពិសេសអំពីក្របខ័ណ្ឌការ ចូលរួមរបស់ជនរងគ្រោះនៅអវតកឡើយ ហើយក៏មិនបាននិយាយអំពី សំណងសម្រាប់ពួកគាត់ផងដែរ។

មាត្រា ៣៦ ថ្មី នៃច្បាប់អវតក និយាយថា *អង្គជំនុំជម្រះនៃតុលាការកំពូលជំនុំជម្រះលើ បណ្តឹងសារទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និងរបស់សហព្រះរាជអាជ្ញាពីសាលដីកា របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងករណីនេះ តុលាការកំពូលពិនិត្យ និងសម្រេចជាចុងក្រោយ ទាំងអង្គហេតុ ទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គ ជំនុំជម្រះវិសាមញ្ញនៃ សាលា ដំបូងវិញទេ។*

ការចែងថា ជនរងគ្រោះមានសិទ្ធិប្តឹងសារទុក្ខ មានន័យយ៉ាងណាចំពោះការចូលរួម របស់ជនរងគ្រោះ?
ភាពមិនច្បាស់លាស់នេះធ្វើឲ្យសេចក្តីព្រាងអត្ថបទនៃជំបូងវិធានផ្ទៃក្នុង មិនចែងពីដើមបណ្តឹងឡើយ។ តាមរយៈការតស៊ូមតិជាខ្លាំងពីសំណាក់ជនរងគ្រោះ និងសង្គមស៊ីវិល ទើបបង្កើត ឲ្យមានការចែងពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងវិធានផ្ទៃក្នុងនេះ។

អ្វីដែលចែងដោយវិធានផ្ទៃក្នុងគឺការចូលរួមរបស់ជនរងគ្រោះ គឺជាការចូលរួមបែបអន្តរាគមន៍។ មានន័យថា បន្ទាប់ពីមានការចោទប្រកាន់ពីសហព្រះរាជអាជ្ញា រឿងក្តីត្រូវបានបញ្ជូន មកចៅ ក្រមស៊ើបអង្កេត ទើបពេល នោះហើយទើបជនរងគ្រោះអាចចូលរួមក្នុងការប្តឹង និងផ្តល់ ព័ត៌មាន របស់ខ្លួនបាន។ ជនរងគ្រោះមិនត្រូវបានអនុញ្ញាតឲ្យដាក់ ពាក្យសុំធ្វើជាចដើមបណ្តឹង រដ្ឋប្បវណីនៅដំណាក់កាលព្រះរាជអាជ្ញានោះទេ។

វិធាន ២៣ស្ទួន (២) *ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យ សុំជាលាយលក្ខអក្សរ យ៉ាងយូរ១៥ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគី ទាំងអស់ពីការបញ្ចប់ការស៊ើបសួរ....*។

លុះត្រាតែចៅក្រមស៊ើបអង្កេតបានទទួល សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទើប មានការបើកឲ្យដាក់ពាក្យសុំជាដើមបណ្តឹង ហើយការដាក់ពាក្យនេះអាចត្រូវបានធ្វើរហូតដល់ ១៥ ថ្ងៃបន្ទាប់ពីការប្រកាសបញ្ចប់ការស៊ើបសួរ។ នេះជាអ្វីដែលបានអនុវត្តនៅករណី ០០១ ០០២,និងករណីបន្តបន្ទាប់។

ចំនុចនេះវាខុសពីករណីរឿងព្រហ្មទណ្ឌសាមញ្ញនៅចំពោះមុខតុលាការជាតិ ដែល ជនរងគ្រោះអាចជាអ្នកដាក់ពាក្យប្តឹង ពីដំបូងទៅ នគបាលយុត្តិធម៌ ព្រះរាជអាជ្ញា(មាត្រា ៦, ៧៣ និង ៤០ កនព) ឬតាមបែបជាអន្តរាគមន៍ទៅចៅក្រមស៊ើបអង្កេត (១៣៨៖ បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)។

ការចូលជាភាគីដោយជនរងគ្រោះត្រូវធ្វើតាមរយៈការដាក់ពាក្យសុំ នៅចំពោះមុខចៅក្រមស៊ើបអង្កេត (គេប្រើពាក្យតាមច្បាប់ អវតក ដែលធ្វើមុនមានក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ)។

នៅពេលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះមិនត្រូវបានទទួលស្គាល់ ជាដើមបណ្តឹងរដ្ឋប្បវេណីដោយស្វ័យប្រវត្តិនោះទេ។ ថានៈជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានការពិនិត្យ និងទទួលស្គាល់ដោយ ចៅក្រម។

នៅក្នុងករណី០០២ សមត្ថកិច្ចទទួលស្គាល់នេះ ជារបស់សហចៅក្រមសអង្កេត និងបើ មិនសុខចិត្តនឹងសេចក្តីសម្រេចនេះ នឹងអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅ អង្គបុរេជំនុំជម្រះ។ សូម បញ្ជាក់ថា អង្គបុរេជំនុំជម្រះនេះ មានតួនាទីដោះស្រាយបញ្ហាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត ចំ ពោះបញ្ហាណាដែលមិនទាន់ចូលក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង មានន័យថាចំពោះកិច្ចនៃនីតិវិធីទាំងឡាយដែល ស្ថិតនៅមុនដំណាក់កាលជំនុំជម្រះ។ នៅក្នុងករណី ០០១(ឌុច) មានការទទួលស្គាល់ជាបណ្តោះអាសន្នថាជាដើមបណ្តឹង រដ្ឋប្បវេណីដោយចៅក្រមស៊ើបអង្កេត និងសមត្ថកិច្ចនៃការសម្រេចពីភាពអាចទទួលថាជាដើមបណ្តឹងរដ្ឋប្បវេណីជារបស់សាលា ដំបូង និងបើមិនសុខចិត្ត អាចប្តឹងសារទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល។នៅពេលត្រូវបានទទួលស្គាល់ រួចហើយ ជនរងគ្រោះបានទទួលសិទ្ធិជាភាគីពេញសិទ្ធិ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ពួកគាត់ មានសិទ្ធិជាភាគី និងអាធ្វើកិច្ចនៃនីតិវិធីដូចភាគីដ៏ទៃទៀតដែរ។

## ២. គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ

យោងតាមវិធាន២៣ អ.វ.ត.ក បណ្តឹងសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គ ជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖

- ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង
- ទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាន ២៣ ស្ទួនបួន[1]។

## ៣. លក្ខខណ្ឌក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ ៖

- បង្ហាញពីអត្តសញ្ញាណឲ្យបានច្បាស់លាស់
- បង្ហាញ ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។

នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ[2]។

## ៤.អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

### ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមជាលក្ខណៈបុគ្គល នៅក្នុងដំណាក់កាលមុនជំនុំជម្រះ។ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវរួមបញ្ចូលក្រុមតែមួយដែលផលប្រយោជន៍របស់ពួកគាត់ត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងវិធាន១២ ស្ទួនពីរ នៃវិធានផ្ទៃក្នុង[3]។

### សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

**ក) សិទ្ធិជាមូលដ្ឋាន**

- សិទ្ធិជាមូលដ្ឋាន គឺសិទ្ធិទទួលបានយុត្តិធម៌។

**ខ) សិទ្ធិទទួលបានតំណាងផ្លូវច្បាប់**

- សិទ្ធិទទួលបានមេធាវីតំណាងដោយមិនគិតកម្រៃ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីនោះក្រីក្រ
- សិទ្ធិក្នុងការទទួលព័ត៌មាន និងជជែកពិភាក្សាជាមួយមេធាវីរបស់ខ្លួនអំពីផលប្រយោជន៍របស់គាត់។

---

[1] វិធាន ២៣(១) នេះវិធានផ្ទៃក្នុង

[2] វិធាន ២៣ ស្ទួន(១) នៃវិធានផ្ទៃក្នុង

[3] វិធាន ២៣ (៣) នៃវិធានផ្ទៃក្នុង (វិ.លើកទី៨)

**គ) សិទ្ធិទទួលបានព័ត៌មាន**

- សិទ្ធិទទួលបានព័ត៌មានស្ដីពីសាលាក្ដីខ្មែរក្រហម
- សិទ្ធិទទួលបានព័ត៌មានអំពីករណីផ្ទាល់ខ្លួនគាត់នៅក្នុងសំណុំរឿង
- សិទ្ធិទទួលបានការពន្យល់ប្រាប់អំពីនីតិវិធីរបស់សាលាក្ដីខ្មែរក្រហមនៅគ្រប់ដំណាក់
- សិទ្ធិទទួលបានការពន្យល់អំពីខ្លឹមសារនៃពាក្យគន្លឹះច្បាប់ ជាពិសេសទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះក្នុងសាលាក្ដីខ្មែរក្រហម។

**ឃ) សិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី**

- សិទ្ធិក្នុងការចូលរួមនៅក្នុងនីតិវិធីរបស់សាលាក្ដីខ្មែរក្រហម
- សិទ្ធិធ្វើសក្ខីកម្ម(បំភ្លឺ) នៅក្នុងពេលសវនាការ (ថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ឬ/ដោយ ផ្ទាល់មាត់)
- សិទ្ធិក្នុងការដាក់សំណើនានាទៅតុលាការពាក់ព័ន្ធនឹងកិច្ចនៃនីតិវិធី
- សិទ្ធិក្នុងការស្នើសុំសំណងសមូហភាព និងផ្លូវចិត្ត
- សិទ្ធិក្នុងការស្នើសុំឲ្យមានវិធានការការពារទៅសាលាក្ដីខ្មែរក្រហម
- សិទ្ធិប្ដឹងបន្តទៅតុលាការថ្នាក់លើតាមការកំណត់របស់ច្បាប់

<u>សិទ្ធិទទួលបានសំណង៖ អាជ្ញាយុកាល លក្ខណៈនៃសំណង</u>

សំណងមានរួមបញ្ចូលវិធានការជាបុគ្គល ឬសមូហភាពក្នុងការដោះស្រាយកំហុសដែលប្រព្រឹត្តលើជនរងគ្រោះនៃការរំលោភសិទ្ធមនុស្ស។ នេះមានរួមបញ្ចូលការប្ដឹងទៅតុលាការក៏ដូចជាវិធានការ ដែលផ្ដល់សំណងផ្លូវចិត្តដូចជាការទទួលស្គាល់ជាផ្លូវការនូវទំនួលខុសត្រូវរបស់រដ្ឋ សកម្មភាពរំលឹកវិញ្ញាណខ័ន្ធនិងការកសាងស្តូបក៏ដូចជាការទូទាត់ប្រាក់។ សិទ្ធិទទួលបាននូវសំណងត្រូវបានបែងចែកជាធាតុផ្សំចំនួន ៤គឺ ការប្រគល់ឲ្យវិញ (restitution) ការទូទាត់ (compensation) ការស្តារនីតិសម្បទា (rehabilitation), ការបំពេញអ្វីដែលចង់បាននិងការធានាមិនឲ្យកើតមានទៀត (satisfaction and guarantees of non-repetition)។

**៥. បទល្មើសដែលត្រូវបានចោទប្រកាន់ នៅអវតក និងការបំបែករឿងក្ដី**

<u>**បទចោទប្រកាន់សំខាន់ៗនៅក្នុងសំណុំរឿង ០០២៖**</u> ជនជាប់ចោទាំងពីរ( គឺលោក នួន ជា និង លោក ខៀវ សំផន) ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ តាមរយៈអំពើរបស់គាត់ ឬការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមដែលបានរៀបចំផែនការ ការញុះញង់ បញ្ជា ជួយ និងសមគំនិត ឬជាអ្នកទទួលខុសត្រូវក្នុងនាមជាអ្នកមើលពីលើឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ បទឧក្រិដ្ឋដែលត្រូវបានចោទលើពួកគាត់គឺ៖

**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖** អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ជាទាសករ ការធ្វើទារុណកម្ម ការរើសអើងដោយមូលហេតុនយោបាយ ឬសាសនា ការជម្លៀសប្រជាជន ការឃុំ- ឃាំង ការរំលោភបំពាន ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖** ឧក្រិដ្ឋកម្មសង្គ្រាម

**អំពើប្រល័យពូជសាសន៍** ៖ ការសម្លាប់រង្គាលលើជនជាតិចាម និងជនជាតិវៀតណាម។

**បទល្មើសខាងលើនេះមានវិសាលភាពលើ៖** ការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំចំនួនបីលើក។ សហករណ៍ និងការដ្ឋាន ចំនួន ៥កន្លែង។ មន្ទីរសន្តិសុខចំនួន ១១កន្លែង និងវាលពិឃាតចំនួន៣ កន្លែង។ ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម វៀតណាម និងពុទ្ធសាសនិក។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

<u>ការបំបែកសំណុំរឿង ០០២ ទៅជាផ្នែកតូចៗគឺ ៖</u>

- *<u>អង្គហេតុនៅក្នុងសំណុំរឿង ០០២/០១៖</u>*

វិសាលភាពនៃការជំនុំជម្រះមាន ៖ ប្រវត្តិ និងរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ។ តួនាទីរបស់សហជនជាប់ចោទ មុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលតួនាទីរបស់ពួកគេត្រូវ បានចាត់តាំង ការទទួលខុសត្រូវរបស់ពួកគេ ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែ បណ្តាញទាក់ទង។ ការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៥ ("ដំណាក់កាលទី១ "។ ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល (ឧត្តរចាស់) និរតី បស្ចិម និងភូមិភាគបូព៌ា ចាប់ពី ខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ១៩៧៧ ("ដំណាក់កាលទី២") ហើយនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិចំនួនប្រាំ (ការធ្វើ មនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុ ផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ) ប៉ុន្តែក្នុងវិសាលភាពដែលឧក្រិដ្ឋកម្មទាំងនេះពាក់ព័ន្ធទៅនឹងដំណាក់កាលទី១ និងដំណាក់កាល ទី២ប៉ុណ្ណោះ។ ការសម្លាប់ទាហានរបបសាធារណៈរដ្ឋខ្មែរនៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ភ្លាមៗក្រោយថ្ងៃខ្មែរ ក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ និងកន្លែងសម្លាប់មនុស្សក្នុងស្រុក ១២។

អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានចង្អុលបង្ហាញផងដែរថា ៖ អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទៅបី នឹងមិនត្រូវបានលើកយក មកដេញដោលនៅក្នុងការជំនុំជម្រះលើកដំបូងនេះទេ។ លើសពីនេះទៀត បទចោទប្រកាន់ទាំងអស់ ដូចជា បទប្រល័យពូជ សាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ត្រូវទុកដើម្បីលើកយកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ក្រោយៗទៀតនៅក្នុងសំណុំរឿង ០០២។

- *<u>អង្គហេតុនៅក្នុងសំណុំរឿង ០០២/០២</u>*

ដោយយោងតាម សេចក្តីបង្គាប់របស់ អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿង ០០២/០២ នឹងត្រូវរួមបញ្ចូលជា អប្បបរមានូវបទចោទ ទាក់ទងនឹង ស-២១ ការដ្ឋានធ្វើការ(៥) សហករណ៍(១) និងបទប្រល័យពូជសាសន៍(ការសម្លាប់ រង្គាលលើជនជាតិចាម និងជនជាតិវៀតណាម)។

- *<u>អង្គហេតុនៅក្នុងសំណុំរឿង ០០២ ផ្សេងទៀតដែលនៅសេសសល់ពី សំណុំរឿង ០០២/០២</u>*

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការជម្លៀសដោយបង្ខំ ដំណាក់កាលទី ៣។

**៦. ទម្រង់នៃការទទួលខុសត្រូវនៅអវតក(សហឧក្រិដ្ឋកម្មរួម) និងករណីសមគំនិត ផ្តើមគំនិត**

សហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តនៅក្នុងក្រមខណ្ឌនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ វាត្រូវបានគេហៅថា JCE(Joint Criminal Entreprise) និងត្រូវបានបង្កើតឡើង នៅ ក្នុងរឿងក្តី Tadic។ ទម្រង់សម្រាប់ការទទួលខុសត្រូវនេះសម្រាប់អនុវត្តក្នុងករណីមនុស្សមួយ ក្រុម ដែលប្រព្រិត្តឧក្រិដ្ឋកម្មរួមគ្នា។ ទម្រង់ទទួលខុត្រូវនេះមានចំនួន៣គឺ៖

ក) ទម្រង់នៃការទទួលខុសត្រូវទី ១ គឺជាទម្រង់មូលដ្ឋាន (Basic form) វាសំដៅលើករណីនៅពេលដែលអ្នកចូលរួមទាំងឡាយបានប្រព្រឹត្តដោយផ្អែកលើផែនការរួម ឬគ្រោងការណ៍រួម ហើយមានចេតនាដូចគ្នាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ទោះបីសហចារីនីមួយៗមានតួនាទី ខុសគ្នានៅក្នុងការសម្រេចផែនការនេះ ក៏ដោយ។ សហឧក្រិដ្ឋកម្មរួម១ ទាមទារឲ្យមានចេតនារួម ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម។

ខ) ទម្រង់នៃការទទួលខុសត្រូវទី ២ គឺជាទម្រង់ជាប្រព័ន្ធ (systematic form) កើតមាននៅពេលអ្នកចូលរួមពាក់ព័ន្ធនៅក្នុងផែនការឧក្រិដ្ឋកម្មមួយ ដែលបានអនុវត្តនៅក្នុងក្របខណ្ឌ ឬជាសមាជិក នៃស្ថាប័ន អង្គភាពកងទ័ព ឬអង្គភាពរដ្ឋបាល ដូចជាក្នុងឋានៈខ្លួនជាអ្នកដឹកនាំជំរុំប្រមូលផ្តុំ ឬឃុំខ្លួនដែលពាក់ព័ន្ធនឹងប្រព័ន្ធធ្វើបាបដែលមានការចាត់តាំង។ សហឧក្រិដ្ឋកម្មរួម ២ មានលក្ខណៈខុស គ្នាបន្តិចពីសហឧក្រិដ្ឋកម្មរួម១ ។ សហឧក្រិដ្ឋកម្មរួម ២ ទាមទារឲ្យបុគ្គលដឹងឮដោយខ្លួនឯង ចំពោះ ប្រព័ន្ធនៃការធ្វើបាបឬប្រព័ន្ធឧក្រិដ្ឋកម្ម និងចេតនាចង់សម្រេចតាមរយៈប្រព័ន្ធនេះថែមទៀត។

គ) ទម្រង់នៃការទទួលខុសត្រូវទី ៣ គឺជាទម្រង់ពន្លាត(extended form)។ សហឧក្រិដ្ឋកម្មរួម ៣ កើតមាននៅពេលអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមទាំងឡាយ ពាក់ព័ន្ធនឹងអំពើដែលកើតឡើងហួសពីផែនការឧក្រិដ្ឋ។ ប៉ុន្តែអំពើទាំងនោះជាផលវិបាកដែលអាចមើលឃើញ និងកើតឡើងដោយឯកឯងនៃការសម្រេចផែនការណ៍រួម។ សហឧក្រិដ្ឋកម្មរួម ៣ ទាមទារឲ្យមានចេតនាក្នុងការចូលរួមនៅក្នុងផែនការឧក្រិដ្ឋ ឬបំណងសហឧក្រិដ្ឋកម្ម និងចេតនាក្នុងការចូលរួមចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម "ដោយមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រៅផែនការ ដែលជនជាប់ចោទអាចប្រមើលមើលឃើញនូវការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួន ហើយស្ម័គ្រចិត្តប្រថុយប្រថាន" ខ្ជីខ្ជារ/មិនចាត់ វិធានការទប់ស្កាត់ ឬនិយាយម្យ៉ាងទៀត "ទោះបីជាដឹងមុនថាបទល្មើសបែបនេះ អាចជាផលវិបាក នៃប្រព្រឹត្តរបស់សហគ្រាសហើយនោះ ហើយទោះជាមានការដឹងបែបនេះក្តី (ក៏បានសម្រេចចិត្ត) ចូលរួមនៅក្នុងសហគ្រាសនោះ" ។

# កិច្ចពិភាក្សាពេលព្រឹក៖ តំណាងដើមបណ្តឹងរដ្ឋប្បវេណី – សេចក្តីសង្ខេបនៃសកម្មភាពបែបអន្តរកម្ម

រៀបរៀងដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក

## ការបំពេញការងារជាមួយកូនក្តី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី

ករណីសិក្សានេះប្រៀបដូចជាការពិគ្រោះយោបល់លើកដំបូងរបស់មេធាវី ដែលនឹងធ្វើឡើងជាមួយកូនក្តីរបស់ខ្លួន ដែលជាដើមបណ្តឹងរដ្ឋប្បវេណី។ សំណួរដែលសិក្ខាកាមក្នុងសិក្ខាសាលានឹងដោះស្រាយនោះ ដំបូងគឺផ្តោតទៅលើក្រមសីលធម៌របស់មេធាវី ហើយបន្ទាប់មកគឺផ្តោតទៅលើបញ្ហានីតិវិធី និងសំណួរសំខាន់ៗនៃច្បាប់ព្រហ្មទណ្ឌ ដែលនឹងត្រូវបានលើកយកមកពិភាក្សាជាមួយកូនក្តី។

### ករណីសិក្សា

ស្ត្រីម្នាក់បានណាត់អ្នកដើម្បីជួបជាមួយគាត់ និងកូនស្រីរបស់គាត់ដែលមានអាយុ ១៦ឆ្នាំ។ កូនស្រីរបស់គាត់ប្រាប់ ថា នាងត្រូវបានគេរំលោភបូក កាលពី៣សប្តាហ៍មុន នៅក្នុងសណ្ឋាគារមួយ នារាជធានីភ្នំពេញ។

កូនស្រីរូបនេះរាយការណ៍ថា យុវជនមួយក្រុមមានគ្នា៧នាក់បានវាយ និងចាប់រំលោភនាង ព្រមទាំងបានលួចយកទូរស័ព្ទ និងប្រាក់១០០ ដុល្លារពីនាង។ នាងស្គាល់អត្តសញ្ញាណជនល្មើស៣នាក់ ក្នុងចំណោមជនល្មើស៧នាក់នេះ ប៉ុន្តែនាងចង់ប្រាប់ឈ្មោះតែ២នាក់ប៉ុណ្ណោះ។ ជនល្មើសខ្លះមានអាយុលើសពី១៨ឆ្នាំ ចំណែកជនល្មើសផ្សេងទៀត មានអាយុក្រោម ១៨ឆ្នាំ។

បន្ទាប់ពីអំពើរំលោភនេះមក កូនស្រីរូបនេះពុំបានទៅឲ្យវេជ្ជបណ្ឌិតពិនិត្យភ្លាមៗទេ ប៉ុន្តែនាងនៅតែមានស្នាមជាំលើខ្លួននាងដោយសារត្រូវគេវាយ។ នាងក៏ជឿជាក់ថា អាចមានសាក្សីមួយចំនួនឃើញយុវជនទាំងនេះចូលទៅក្នុងសណ្ឋាគារជាមួយនាង។

### សំណួរ

### ក. ការផ្តល់ប្រឹក្សាដល់កូនក្តី និង សីលធម៌វិជ្ជាជីវៈ

ម្តាយ ព្រមទាំងកូនបានមកជួបអ្នករួមគ្នា

១. តើអ្នកគិតថា អ្នកត្រូវនិយាយជាមួយកូនស្រីដាច់ដោយឡែកដែរឬទេ ?ហេតុអ្វី ?

២. តើមានបញ្ហានៃការរក្សាការសម្ងាត់ដែរឬទេ ?

៣. ពេលក្រោយមក ប្រសិនបើ ម្តាយរបស់នាងឲ្យអ្នកប្រាប់គាត់ នូវអ្វីដែលកូនស្រីរបស់គាត់ប្រាប់អ្នក តើអ្នកជាប់កាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈដែរឬទេ ? បើមិនជាប់កាតព្វកិច្ច ហេតុអ្វី ? បើជាប់កាតព្វកិច្ច ហេតុអ្វី ?

៤. ប្រសិនបើ កូនស្រីប្រាប់អ្នកកុំអោយប្រាប់ម្តាយនាងនូវរឿងរ៉ាវណាមួយ តើអ្នកសន្យាថានឹងរក្សាការសម្ងាត់ដែរឬទេ? ហេតុអ្វីត្រូវសន្យា? ហេតុអ្វីមិនត្រូវសន្យា ?

៥. ដោយយល់ឃើញថា ម្តាយរបស់នាងបាននាំនាងមកពិគ្រោះយោបល់ តើអ្នកត្រូវការពារភាពសម្ងាត់របស់កូនស្រីយ៉ាងដូចម្តេច ?
៦. តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យកូនស្រីប្រាប់អ្នកនូវរឿងរ៉ាវរបស់នាង?

នៅក្នុងពេលសម្ភាសដំបូងជាមួយកូនក្តីរបស់អ្នក នាងបានប្រាប់អ្នកថា នាងត្រូវបានគេរំលោភដោយភ្ជង់កាំបិត។ ប៉ុន្តែ នៅពេលសម្ភាសលើកក្រោយនាងប្រាប់អ្នកថា ពុំមានកាំបិតទេ ប៉ុន្តែនាងត្រូវយុវជនទាំងនោះគម្រាមកំហែង។
៧. តើករណីនេះធ្វើឲ្យយោបល់របស់អ្នកលើរឿងក្តីនេះមានការប្រែប្រួលដោយរបៀបណា?
៨. តើអ្នកនឹងធ្វើអ្វីខុសពីមុននេះទេ?
៩. ហេតុអ្វីបានជានាងផ្លាស់ប្តូររឿងរ៉ាវរបស់នាង?
១០. តើអ្នកមានយោបល់យ៉ាងដូចម្តេចចំពោះភាពផ្ទុយគ្នានេះ ?
១១. តើអ្នកគិតថាហេតុអ្វីបានជានាងនិយាយរឿងដូច្នេះ? (បើអញ្ចឹងមែន វានឹងធ្វើអោយរឿងក្តីកាន់តែធ្ងន់ធ្ងរ?)
១២. តើអ្នកដេញដោលជាមួយនាងដែររឺទេ អំពីភាពមិនស៊ីសង្វាក់គ្នានេះ?
១៣. តើអ្នកទាញសេចក្តីសន្និដ្ឋានយ៉ាងដូចម្តេច ?

កូនស្រីនេះហាក់ដូចជាមានអារម្មណ៍ក្រៀមក្រមពិបាកចិត្តខ្លាំង ក្នុងពេលសម្ភាសជាមួយអ្នក។ នាងរៀបរាប់បញ្ហាមួយ ចំនួនដែលបានកើតឡើងនៅក្នុងទំនាក់ទំនងរបស់នាង និងក្នុងចំណោមគ្រួសារ និងសហគមន៍របស់នាង ចាប់តាំងពីមានការរំលោភសេពសន្ថវៈមក។
១៤ .តើការប្រឹក្សាយោបល់ ឬធនធានអ្វីខ្លះ ដែលអ្នកអាចផ្តល់ឲ្យនាង ដើម្បីជួយដោះស្រាយបញ្ហាទាំងនេះ?
១៥ .តើអ្នកត្រូវតែនៅឲ្យឆ្ងាយពីនាងដែរឬទេ?
១៦. តើអ្នកមានតួនាទីអ្វីខ្លះ?

ក្មេងស្រីនេះ ប្រាប់អ្នកកុំឲ្យបញ្ចេញឈ្មោះជនល្មើសម្នាក់ ដែលនាងស្គាល់។
១៧. តើអ្នកដោះស្រាយសំណើនេះរបៀបណា? តើអ្នកមានកាតព្វកិច្ចត្រូវរក្សាការសម្ងាត់ដែរឬទេ? ឬត្រូវធ្វើផ្ទុយពីនេះ?
១៨. តើអ្នកត្រូវប្រាប់អត្តសញ្ញាណរបស់ជនល្មើសនេះទៅតុលាការដែរឬទេ ?ហេតុអ្វីបានប្រាប់ឬហេតុអ្វីបានជាមិនត្រូវប្រាប់ ?

## ការរៀបចំរឿងក្តី

១៩. តើអ្នកគ្រោងនឹងរៀបចំរឿងក្តីនេះជាមួយជនរងគ្រោះយ៉ាងដូចម្តេច? ឧទាហរណ៍៖ ការណាត់ជួប សំណុំឯកសារ ផ្សេងៗ ។ល។?
២០ .ប្រសិនបើអ្នកទំនងជាមានការលំបាកទាក់ទងនឹងរឿងក្តីនេះ តើអ្នកទៅជួបជនរងគ្រោះ និងម្តាយរបស់នាងដែរឬទេ?
២១. តើអ្នកអាចនឹងជួបការលំបាកអ្វីខ្លះ សូមលើកជាឧទាហរណ៍ ?
២២ .តើអ្នកត្រូវពន្យល់ពីនីតិវិធី និងដំណើរការតាមផ្លូវច្បាប់ដល់នាងយ៉ាងដូចម្តេច?

## ខ. បញ្ហាផ្លូវច្បាប់ផ្នែកនីតិវិធី និង បញ្ហាផ្នែកច្បាប់សំខាន់ៗ

**នីតិវិធី**

២៣ .តើអ្នកពន្យល់ពីកិច្ចដំណើរការនៃកិច្ចនីតិវិធីដោយរបៀបណាខ្លះ? ដូចជា បណ្តឹង ចៅក្រម តួនាទីរបស់ព្រះរាជអាជ្ញា ?...

២៤. តើមេធាវីរបស់ជនរងគ្រោះមានតួនាទីអ្វីខ្លះ នៅក្នុងអំឡុងពេលស៊ើបសួរ? (អំពើប្លន់ អំពើហិង្សា អំពើរំលោភសេពសន្ថវៈ)

២៥ .តើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរអ្វីខ្លះ ដែលអ្នកដាក់ជូនទៅចៅក្រមស៊ើបសួរ?

២៦. ប្រសិនជាអនីតិជន និងនីតិជនត្រូវបានដាក់ឲ្យស្ថិតក្រោមការស៊ើបសួរ តើត្រូវអនុវត្តតាមនីតិវិធីអ្វីខ្លះ?

## ភស្តុតាង

២៧ .តើភស្តុតាងអ្វីខ្លះ ដែលអ្នកត្រូវបង្ហាញ ដើម្បីបញ្ជាក់ថា បទឧក្រិដ្ឋនោះបានកើតឡើង?

២៨ .តើភស្តុតាងអ្វីខ្លះ ដែលអ្នកត្រូវលើកមកបង្ហាញ ដើម្បីគាំទ្រដល់បទចោទប្រកាន់ក្នុងករណីរំលោភសេពសន្ថវៈ?

២៩ .តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីផ្តល់ភស្តុតាង ដូចជា ឈ្មោះសាក្សី ម្ចាស់បណ្តឹង ការស្នើសុំលិខិតបញ្ជាក់ ដូចជា លិខិតពេទ្យ ការពិនិត្យកន្លែងកើតហេតុ។

៣០ .តើបញ្ហាអ្វីខ្លះ ដែលអ្នកពិនិត្យឃើញចំពោះភស្តុតាង ដូចជា ពុំមានភស្តុតាងភ្លាមៗអំពីការរំលោភសេពសន្ថវៈ ពុំមានសាក្សីឃើញផ្ទាល់ភ្នែក។

## ការកំណត់ប្រភេទនៃគតិយុត្តិ

៣១. តើការកំណត់ប្រភេទនៃគតិយុត្តិអ្វី ដែលអ្នកស្នើឡើង ដោយផ្អែកលើភស្តុតាងដែលមាន?

៣២. តើការកំណត់ឈ្មោះបទល្មើសអ្វី ដែលអាចលើកលែងចោទប្រកាន់ ដោយផ្អែកលើការខ្វះភស្តុតាង?

៣៣. ចំពោះការដែលគ្មានភស្តុតាង តើមានផលវិបាកអ្វីខ្លះ ដែលអាចប៉ះពាល់ដល់ការកំណត់ឈ្មោះបទល្មើស?

## សំណង និងការលើកអំណះអំណាង

៣៤. ចំពោះបញ្ហាសំណងជួសជុល/សំណងការខូចខាត តើអ្នកប្រមើលឃើញយ៉ាងដូចម្តេច?

៣៥.តើអ្នកគ្រោងនឹងលើកអំណះអំណាងយ៉ាងដូចម្តេច?

៣៦ .តើអ្នកចង់លើកឡើងនូវបញ្ហាអ្វីខ្លះ នៅក្នុងអំណះអំណាងរបស់អ្នក? តើមានចំណុចអ្វីខ្លះដែលអ្នកយល់ថាមានសារៈសំខាន់?

# កិច្ចពិភាក្សាពេលរសៀលៈ យុទ្ធសាស្ត្រការពារក្តី – សេចក្តីសង្ខេបនៃសកម្មភាពបែបអន្តរកម្ម

រៀបរៀងដោយលោក Victor Koppe សហមេធាវីអន្តរជាតិ សម្រាប់លោក នួន ជា អ.វ.ត.ក

## ករណីសិក្សាៈ រឿងក្តីសម្រាប់មេធាវីការពារក្តីព្រហ្មទណ្ឌ

### ករណីសិក្សា

អ្នកបានជួបប្រជុំជាមួយស្ត្រីម្នាក់នៅក្នុងការិយាល័យរបស់អ្នក កាលពីមួយសប្តាហ៍កន្លងផុតទៅ។ ស្ត្រីនោះបានប្រាប់អ្នកថា កូនរបស់នាងឈ្មោះវិសាលមានអាយុ១៧ឆ្នាំ ត្រូវបានចាប់ខ្លួនដោយនគរបាលនៅក្រុងភ្នំពេញ កាលពី៣ខែមុន។ វិសាលត្រូវបានចោទប្រកាន់រួមជាមួយនឹងមនុស្ស៦នាក់ផ្សេងទៀត ពីបទរំលោភសេពសន្ថវៈលើក្មេងស្រីអាយុ១៦ឆ្នាំម្នាក់នៅទីក្រុងភ្នំពេញ។ វិសាលក៏ត្រូវបានចោទប្រកាន់ផងដែរថា បានលួចទូរស័ព្ទដៃ និងប្រាក់ចំនួន $១០០ របស់នាង។

ម្តាយរបស់វិសាល បានប្រគល់សំណុំរឿងមួយច្បាប់ ដែលគាត់បានទទួលពីមេធាវីមុនដល់អ្នក។ ក្នុងសំណុំរឿងដែលអ្នកបានអាននោះ មានខ្លឹមសារថា ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយ ហើយថា ដំណើរការជំនុំជម្រះនឹងត្រូវចាប់ផ្តើមក្នុងរយៈពេល២សប្តាហ៍ទៀត។ នៅក្នុងសំណុំរឿង អ្នកក៏ឃើញផងដែរនូវចម្លើយសារភាពរបស់វិសាលដែលថា គាត់បានរំលោភសេពសន្ថវៈ មកលើក្មេងស្រីនោះ និងបានលួចទូរស័ព្ទដៃ និងលុយរបស់នាង។

នៅក្នុងសំណុំរឿង មានចម្លើយរបស់សហជនជាប់ចោទម្នាក់ទៀត ឈ្មោះអារុណ ដែលបដិសេធមិនទទួលស្គាល់ថា ខ្លួនបានរំលោភសេពសន្ថវៈមកលើក្មេងស្រីនោះទេ។ អារុណ ដែលត្រូវបានចាប់ខ្លួនផងដែរនោះ បានបញ្ជាក់ប្រាប់នគរបាលថា ខ្លួនមិនបានប្រព្រឹត្តអ្វីទាល់តែសោះ តែថា គាត់បានស្តាប់ឮនៅទីធ្លាសួនច្បារសាលាថា ក្មួយប្រុសរបស់គាត់ដែលជានិស្សិត និងជាកូនប្រុសរបស់មន្ត្រីរដ្ឋាភិបាលសំខាន់ម្នាក់អាចជាប់ពាក់ព័ន្ធ ក្នុងការរំលោភសេពសន្ថវៈនេះ។ បច្ចុប្បន្ននេះ ក្មួយប្រុសរបស់គាត់ ឈ្មោះផល្លា មិននៅក្នុងប្រទេសកម្ពុជាទេ។

នៅក្នុងចម្លើយជាសាក្សីរបស់នាង ក្មេងស្រីនោះផ្តល់សក្ខីកម្មថា នាងត្រូវបានរំលោភសេពសន្ថវៈដោយ វិសាលដែលនាងស្គាល់នៅសាលារៀន និងមនុស្ស៦នាក់ទៀត ដោយរាប់ទាំងអារុណផងដែរ ដែលបានយកទូរស័ព្ទដៃ និងលុយរបស់នាង។ ករណីរំលោភសេពសន្ថវៈបានកើតឡើងកាលពីយប់ថ្ងៃសុក្រ បន្ទាប់ពីកម្មវិធីជប់លៀងមួយនៅក្នុងក្លឹបមួយកន្លែងនាទីក្រុងភ្នំពេញ។

មិនមានរបាយការណ៍ផ្នែកពេទ្យនៅក្នុងសំណុំរឿង ហើយក៏មិនមានសាក្សីក្នុងអំពើរំលោភសេពសន្ថវៈនោះដែរ។

នៅពេលបញ្ចប់ការប្រជុំក្នុងការិយាល័យរបស់អ្នក ម្តាយរបស់វិសាលបានប្រាប់ថា នគរបាលបានវាយតប់ វិសាលយ៉ាងធ្ងន់ធ្ងរអំឡុងពេលសួរចម្លើយ។ ថ្គាមរបស់វិសាលត្រូវបានបែក ហើយគេក៏មិនអាចដើរបានអស់រយៈពេលជាច្រើនសប្តាហ៍។ ដោយសារតែការធ្វើទុក្ខបុកម្នេញនេះហើយ វិសាលបានឆ្លើយសារភាពប្រាប់នគរបាល។ ប៉ុន្តែ វិសាលបានប្រាប់ម្តាយរបស់គេក្នុងពេលសួរសុខទុក្ខក្នុងពន្ធនាគារថា វិសាលមិនមានទោសពៃរ៍អ្វីទេ ហើយថា វិសាលមិនបានប្រព្រឹត្តអ្វីទេក្នុងអំពើរំលោភសេពសន្ថវៈមកលើក្មេងស្រីនោះ។ វិសាលស្គាល់នាង តែពីសាលារៀនប៉ុណ្ណោះ ហើយបានប្រាប់ម្តាយរបស់គាត់ថា ខ្លួនបានបាក់ចិត្តស្រឡាញ់នាង។ ម្តាយរបស់វិសាលបានប្រាប់អ្នកថា គាត់គិតថា ក្មេងស្រីនោះអាចនឹងខ្លាចមិនហ៊ានចោទប្រកាន់និស្សិតម្នាក់ឈ្មោះផល្លា ដែលហាក់ដូចជាមានឪពុកជាអ្នកធំម្នាក់។

ម្តាយរបស់វិសាលមិនមានប្រាក់ច្រើននោះទេ ប៉ុន្តែគាត់ចំណាយចំនួន$១,០០០ ដល់អ្នក ដើម្បីការពាររឿងក្តី នេះ។

នាវេលាព្រឹកនេះ អ្នកបានជួបវិសាលក្នុងពន្ធនាគារ ហើយគាត់បញ្ជាក់បន្ថែមអំពីរឿងរ៉ាវរបស់ម្តាយរបស់គាត់។ វិសាលបញ្ជាក់បន្ថែមថា គាត់ត្រូវវាយតប់ដោយនគរបាលមុនពេលផ្តល់ចម្លើយសារភាព ហើយថា គាត់ពិតជាគ្មានទោសពៃរ៍អ្វីទេ។

ពេលក្រោយមកទៀត អ្នកធ្វើដំណើរត្រឡប់ទៅការិយាល័យវិញ ហើយគិតក្នុងរថយន្តរបស់អ្នកអំពីអ្វី ដែលអ្នកត្រូវបំពេញក្នុងរឿងក្តីនេះ។ អ្នកបានគិតអំពីយុទ្ធសាស្រ្តមួយសម្រាប់ការជំនុំជម្រះរយៈពេល មួយសប្តាហ៍ពេញទៅហើយ។ អ្នកបានធ្វើសេចក្តីសម្រេចមួយចំនួននៅក្នុងរថយន្តរបស់អ្នក ទាក់ទងនឹងអ្វី ដែលអ្នកត្រូវធ្វើអំឡុងពេលជំនុំជម្រះក្តី។

ប៉ុន្តែមុនពេលទៅដល់ការិយាល័យអ្នកសម្រេចថា ទៅញ៉ាំកាហ្វេនៅហាងកាហ្វេBrown ស្ថិតនៅផ្លូវលេខ២១៤។ ខណៈដែលអ្នកញ៉ាំកាហ្វេនោះ ហើយបន្តការគិតអំពីរឿងក្តីនេះ ក៏មានអតីតមិត្តរួមសាលាម្នាក់ដើរសំដៅមក និងនិយាយជំរាបសួរដល់អ្នក។ អ្នកសប្បាយរីករាយណាស់ដោយជួបគាត់ម្តងទៀត។ ឥឡូវនេះ គាត់គឺជាមន្ត្រី ជាន់ខ្ពស់ម្នាក់ក្នុងរាជរដ្ឋាភិបាលនៅភ្នំពេញ។ គាត់សួរអ្នកថា តើគាត់អាចអញ្ជើញអ្នកញ៉ាំកាហ្វេមួយកែវទៀតទេ ព្រោះគាត់ត្រូវការការប្រឹក្សាយោបល់របស់អ្នក។ គាត់ចាប់ផ្តើមជំរាបជូនអ្នកដូចខាងក្រោមនេះ៖

កូនប្រុសរបស់គាត់ឈ្មោះផល្លា ដែលបច្ចុប្បន្ននេះនៅប្រទេសវៀតណាម កំពុងមានបញ្ហា។ នគរបាលបានព្យាយាមចាប់ខ្លួនគាត់កាលពី២ខែកន្លងទៅនេះ តែគាត់មិនបាននៅផ្ទះទេ។ នគរបាលបានរកឃើញហេរ៉ូអ៊ីន ចំនួន១៥០ក្រាម និងកាំភ្លើងខ្លីមួយដើមក្នុងផ្ទះរបស់គាត់។ ក្រោយពី ផល្លាបានឮអំពីការឆែកឆេរផ្ទះរបស់គាត់ ហើយគាត់ក៏រត់គេចទៅប្រទេសវៀតណាម។

លើសពីនេះទៀត មិត្តភ័ក្រ្តរបស់អ្នក ដែលជាមន្រ្តីរដ្ឋាភិបាលប្រាប់អ្នកថា គាត់បានឮផងដែរនូវពាក្យចចាមអារាមពីមិត្តភ័ក្រ្តម្នាក់ក្នុងនាយកដ្ឋាននគរបាលថា កូនប្រុសរបស់គាត់ ឈ្មោះផល្លាអាចពាក់ព័ន្ធក្នុងអំពើរំលោភសេពសន្ថវៈមកលើក្មេងស្រីណាម្នាក់ ហើយថា តាមពិតទៅ នេះគឺជាមូលហេតុដំបូង ដែលនគរបាលព្យាយាមចាប់ខ្លួនគាត់។ កូនប្រុសរបស់គាត់មានការប្រឡងដ៏សំខាន់នាសប្តាហ៍ក្រោយ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ហើយចាំបាច់ត្រូវត្រឡប់មកភ្នំពេញវិញ។ ឪពុករបស់ផល្លាសួរអ្នក ប្រសិនបើ អ្នកអាចជួយ កូនប្រុសរបស់គាត់ ហើយផ្តល់ប្រាក់ចំនួន$១០,០០០ ដល់អ្នក ដើម្បីការពាររឿងក្តីនេះ។

## សំណួរ

១. មុនពេលទទួលទានកាហ្វេនៅហាងBrown អ្នកបានសម្រេចនូវយុទ្ធសាស្រ្តមួយ ដើម្បីការពារក្តីរបស់វិសាល។ តើយុទ្ធសាស្រ្តអ្វីខ្លះអ្នកបានសម្រេចដាក់ចេញ ដើម្បីសួរដេញដោលលើភស្តុតាងអំឡុងពេលនៃការជំនុំជម្រះក្តី? ចូរលើកឡើងឲ្យបានជាក់លាក់អំពីបញ្ហានានាទាក់ទងនឹងចម្លើយសារភាព ដោយបង្ខំនៃកូនក្តីរបស់អ្នក អំពីភាពជឿជាក់បានរបស់ក្មេងស្រីនោះ ចម្លើយរបស់អារុណ អវត្តមាននៃភស្តុតាងផ្នែកពេទ្យ ។ល។ ហើយចូរសំរេច ផងដែរថា តើកូនក្តីរបស់អ្នកគួរឆ្លើយសំណួរពីចៅក្រម និងព្រះរាជអាជ្ញាអំឡុងពេលជំនុំជម្រះឬទេ?

២. តើអ្នកប្រាប់អតីតមិត្តភ័ក្រ្តរបស់អ្នកយ៉ាងដូចម្តេចនៅហាងកាហ្វេBrown បន្ទាប់ពីគាត់បាននិយាយប្រាប់នូវរឿងរ៉ាវអំពីកូនប្រុសរបស់គាត់ ឈ្មោះផល្លា?